ប្រការ ៣ : មានសិទ្ធិក្នុងការទាក់ទងគ្រប់នាយកដ្ឋាន អគ្គសេនាធិការយោធភូមិភាគ តំបន់ប្រតិបត្តិការសឹករង អង្គភាពកងអាកាសចរណ៍ខេមរភូមិន្ទ និង កងនាវាចរណ៍ខេមរភូមិន្ទ ក្រសួងមហាផ្ទៃនិងសន្តិសុខ ដើម្បីប្រមូលនូវពត៌មានណាដែលសំខាន់ក្នុងកិច្ចការការពារជាតិ ។

ប្រការ ៤ : ទីប្រឹក្សានឹងត្រូវបានទទួលភារកិច្ចបន្ថែមតាមការសំរេចរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ ។

ប្រការ ៥ : សហរដ្ឋមន្ត្រីទទួលបន្ទុក ទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃនិងសន្តិសុខ នាយអគ្គសេនាធិការនៃកងយោធពលខេមរភូមិន្ទ មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី២ |
|---|---|
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| នរោត្តម រណឫទ្ធិ | ហ៊ុន សែន |

* * *

## អនុក្រឹត្យលេខ ៣៧ អនក្រ

## ស្តីពីការបែងចែកសិទ្ធិចុះហត្ថលេខាលើ
## អត្តសញ្ញាណប័ណ្ណ នាយទាហាន នាយទាហានរង
## និង ពលទាហាន ក្នុងជួរ កងយោធពលខេមរភូមិន្ទ

*ភ្នំពេញថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៤*

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញក្រឹត្យចុះថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ១៩៩៣ ស្តីពីការចាត់តាំងបង្កើតក្រសួងការពារជាតិ និង អគ្គសេនាធិការដ្ឋាន

-យោងតាមព្រះរាជក្រឹត្យ ព្រះបាទសម្តេចព្រះនរោត្តម សីហនុវរ្ម័ន រាជហរិវង្សឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និង នរោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- យោងតាមសំណើរបស់ក្រសួងការពារជាតិ អគ្គសេនាធិការ

**សំរេច**

មាត្រា១:-ត្រូវបានប្រគល់សិទ្ធិអោយក្រសួងការពារជាតិ និង អគ្គសេនាធិការ ចុះហត្ថលេខា លើអត្តសញ្ញាណប័ណ្ណ នាយទាហាន នាយទាហានរង ពលទាហាន ក្នុងកងយោធពលខេមរភូមិន្ទ ចាប់ពីយោធិន ដែលមានឋានន្តរសក្តិ ថ្នាក់វរៈសេនីយឯកចុះ ។

មាត្រា ២ : សហរដ្ឋមន្ត្រីក្រសួងការពារជាតិមានសិទ្ធិចុះហត្ថលេខាលើអត្តសញ្ញាណប័ណ្ណ នាយទាហាន ដែលស្ថិតចំណុះផ្ទាល់របស់ក្រសួងការពារជាតិ និង មានឋានន្តរសក្តិ ចាប់ពីថ្នាក់វរៈសេនីយឯកដល់នាយចំណាង ។

-នាយអគ្គសេនាធិការ មានសិទ្ធិចុះហត្ថលេខាលើអត្តសញ្ញាណប័ណ្ណ នាយទាហាន ដែលស្ថិតចំណុះផ្ទាល់របស់អគ្គសេនាធិការ និង មានឋានន្តរសក្តិចាប់ពីថ្នាក់វិរៈសេនីយឯកដល់នាយចំណាង ។

ចំពោះនាយទាហានរង ពលទាហាន ដែលមានឋានន្តរសក្តិពីថ្នាក់ព្រិន្ទបាល-ឯកដល់ ពលទោ អាស្រ័យដោយសហរដ្ឋមន្ត្រីក្រសួងការពារជាតិ និង នាយអគ្គសេនាធិការ ប្រគល់សិទ្ធិជាក់ស្តែង ។

មាត្រា ៣:-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ នាយអគ្គសេនាធិការត្រូវទទួលបន្ទុកអនុវត្តន៍តាមអនុក្រឹត នេះចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

| នាយករដ្ឋមន្ត្រីទី១ | នាយករដ្ឋមន្ត្រីទី២ |
|---|---|
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ | សម្តេច ហ៊ុន សែន |

* * *